# កំណាព្យ

## កើតជាមនុស្ស

បទភុជង្គលីលា

កើតជាមនុស្សមានសំណាង
តែត្រូវចេះសាង ទើបបានស្គាល់សុខ។
ព្យាយាមបោះបង់ចោលទុក្ខ
ដែលជាជម្រុក ចាប់ផ្តុកក្នុងចិត្ត។

ជួបវេទនាថាជាកម្ម
រស់នៅក្នុងខន្ធ[1] មានកត់ក្នុងធម៌។
តែផ្លូវវាសនាមានខ[2]
ពុទ្ធវាទបវរ នាំចរឆ្លងទុក្ខ។

វដ្តសង្សារ[3]ជាប្រភព
ទុក្ខកម្មសព្វគ្រប់ រំលត់ដោយចិត្ត
មានព្រះ[4]ដ៏ល្អវិចិត្រ
នាំឱ្យចរិត កំរិតផ្លូវត្រូវ។

[1] ខន្ធ : ន. កំណត់ : ខន្ធ៥ គឺ រូបខន្ធ, វេទនាខន្ធ, សញ្ញាខន្ធ, សង្ខារខន្ធ, វិញ្ញាខន្ធ។
[2] ខ : ន. មាត្រា។
[3] វដ្តសង្សារ : ដំណើរមន្ទោលវិលកើតស្លាប់។
[4] មានព្រះ : មានធម៌ក្នុងចិត្ត។